# ព្រឹត្តិបត្រព័ត៌មាន NEC BULLETIN គ.ជ.ប

លេខ ១ ចេញផ្សាយថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១


# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០១១



## សេចក្តីអំពាវនាវរបស់ឯកឧត្តម អ៊ឹម សួស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## បណ្តុះបណ្តាលមន្ត្រីបោះឆ្នោត និងមន្ត្រីតំណាងស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត

## បទសម្ភាសន៍ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប ជាមួយទូរទស្សន៍ជាតិកម្ពុជា




### មាតិកា


- សេចក្តីអំពាវនាវរបស់ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប..........................ទំព័រទី ២
- វគ្គបណ្តុះបណ្តាលមន្ត្រីបោះឆ្នោត និងមន្ត្រីតំណាងស្ថាប័នពាក់ព័ន្ធ...................ទំព័រទី ៣
- លេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តមណ្ឌលគិរី បើកវគ្គបណ្តុះបណ្តាល.....ទំព័រទី ៦
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលផុតពេលកំណត់ប្រើប្រាស់ត្រូវបានបន្ត.........ទំព័រទី ៧
- បទសម្ភាសន៍ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប ......................................ទំព័រទី ៨
- ប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១...............ទំព័រទី ១៣
- ប្រតិទិននៃការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ....ទំព័រទី ១៤
- ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣............ទំព័រទី ១៥



necinfo@forum.org.kh www.necelect.org.kh Fax/Phone: (023) 214 374, 214231, Tel: 012 855 018





# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**សេចក្តីអំពាវនាវ**
**របស់ ឯកឧត្តម អ៊ឹម សូស៊ី**
**ប្រធាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ក្រោយមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១មក នៅព្រះរាជាណាចក្រកម្ពុជា មានរៀបចំបោះឆ្នោតចំនួន៨លើករួចមកហើយ ពោលគឺការបោះឆ្នោតជ្រើសរើសសភាធម្មនុញ្ញឆ្នាំ១៩៩៣ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ១៩៩៨-២០០៣-២០០៨ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០២-២០០៧ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឆ្នាំ២០០៦ និងការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ឆ្នាំ២០០៩ ។

ការបោះឆ្នោតកន្លងមកបានសំដែងឱ្យឃើញថា លទ្ធិប្រជាធិតេយ្យ និងការគោរពសិទ្ធិមនុស្សនៅកម្ពុជាកំពុងត្រូវបានពង្រឹង ។ ដូច្នេះដើម្បីឱ្យលទ្ធិប្រជាធិបតេយ្យនៅប្រទេសយើងកាន់តែរឹងមាំនោះយើងទាំងអស់គ្នាត្រូវតែទៅបោះឆ្នោត ។

ខ្ញុំសូមជំរាបបងប្អូនប្រជាពលរដ្ឋទូទាំងប្រទេសមេត្តាជ្រាបថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ នឹងប្រព្រឹត្តទៅនៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១២ ។ ដើម្បីបោះឆ្នោតបានបងប្អូនប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួនក្នុងពេលបោះឆ្នោត ។

ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតមានរយៈពេល ៤៥ថ្ងៃ នឹងចាប់ផ្តើមដំណើរការពីថ្ងៃទី ០១ ខែកញ្ញា ដល់ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១១ ។ ក្នុងនាម **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** ខ្ញុំសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋដូចតទៅ :

១- ចំពោះបងប្អូនប្រជាពលរដ្ឋ ដែលធ្លាប់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់របស់ខ្លួនរួចហើយ សូមអញ្ជើញទៅពិនិត្យមើលឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ (បញ្ជីបោះឆ្នោតឆ្នាំ២០១០) ដែលមានបិទផ្សាយនៅតាមសាលាឃុំ សង្កាត់ និងនៅតាមទីកន្លែងណាមួយក្នុងឃុំ សង្កាត់ ចាប់ពីថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១១ ។ ក្នុងករណីពិនិត្យមើលក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ឃើញមានខុសទិន្នន័យក្នុងចំណុចណាមួយ ដូចជាឈ្មោះ ភេទ ថ្ងៃ ខែ ឆ្នាំកំណើត ទីលំនៅ សូមអញ្ជើញទៅជួបស្មៀនឃុំ សង្កាត់ ដើម្បីសុំកែតម្រូវចាប់ពីថ្ងៃទី០១ ខែកញ្ញា រហូតដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១១ ខាងមុខនេះឱ្យទាន់ពេលវេលា ។

២- ចំពោះបងប្អូនប្រជាពលរដ្ឋ ដែលដែលទើបផ្លាស់ប្តូរទីលំនៅចូលពីឃុំ សង្កាត់ផ្សេង អ្នកពុំធ្លាប់បានចុះឈ្មោះបោះឆ្នោត អ្នកទើបគ្រប់អាយុ១៨ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត( ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០១២ )សូមអញ្ជើញទៅសុំចុះឈ្មោះបោះឆ្នោត ដោយផ្ទាល់នៅតាមសាលាឃុំ សង្កាត់ ឬនៅតាមទីតាំងណាមួយក្នុងឃុំ សង្កាត់ដែលបងប្អូនកំពុងរស់នៅចាប់ពីថ្ងៃទី០១ ខែកញ្ញា រហូតដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១១ ដោយត្រូវយកទៅជាមួយនូវឯកសារមួយ ឬច្រើនដែលអាចបញ្ជាក់លក្ខខណ្ឌ៤យ៉ាង គឺ អត្តសញ្ញាណ សញ្ជាតិ អាយុ និង ទីលំនៅ ។

ឯកសារទាំងនោះមានដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល អត្តសញ្ញាណប័ណ្ណនគរបាលជាតិ អត្តសញ្ញាណប័ណ្ណកងយោធពលខេមរភូមិន្ទ ប័ណ្ណសម្គាល់ខ្លួនក្រសួងស្ថាប័ន លិខិតឆ្លងដែនជាដើម ។

៣- សូមអំពាវនាវដល់ ស្ថាប័នជាតិនានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ គណបក្សនយោបាយ សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល រោងចក្រ សហគ្រាស ក្រុមហ៊ុន សូមបង្កលក្ខណៈល្អ និងជំរុញលើកទឹកចិត្ត ដល់មន្ត្រីរាជការ បុគ្គលិក កម្មករ ក្រោមឱវាទ ក៏ដូចជាប្រជាពលរដ្ឋទាំងអស់ឱ្យទៅពិនិត្យមើលបញ្ជីឈ្មោះ និងចុះឈ្មោះឱ្យបានគ្រប់ៗគ្នា និងទាន់ពេលវេលា ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សង្ឃឹមជឿជាក់យ៉ាងមុតមាំ លើស្មារតីចូលរួមរបស់ប្រជាពលរដ្ឋទាំងអស់ និងកិច្ចសហប្រតិបត្តិការ របស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងជំរុញឱ្យការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះពេលខាងមុខនេះសម្រេចបានលទ្ធផលល្អជាក់ជាមិនខាន ។

សូមអរគុណ

ភ្នំពេញ ថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១១

ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម_សូស៊ី



# វគ្គបណ្តុះបណ្តាលមន្ត្រីបោះឆ្នោត និងមន្ត្រីតំណាង ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត

កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានបើកការបណ្តុះបណ្តាលរយៈពេល១ថ្ងៃ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ ដល់មន្ត្រីនៅទីស្តីការ គ.ជ.ប មន្ត្រីមកពីលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត(លធ/ខប)ទាំង២៤ តំណាងគណបក្សនយោបាយ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលសរុបប្រមាណជាង១០០នាក់។




ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប មានមតិណែនាំក្នុងវគ្គបណ្តុះបណ្តាល

មានមតិណែនាំក្នុងពិធីនោះ ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានលើកឡើងថា ចាប់ពីខែកញ្ញាទៅ យើងមានការងារច្រើនដែលត្រូវធ្វើ ហើយសូមឱ្យមន្ត្រី លធ/ខប ទាំងអស់យកចិត្តទុកដាក់ និងពង្រឹងការងាររបស់ខ្លួនឱ្យបានខ្លាំងក្លា។ ឯកឧត្តមបានបញ្ជាក់ថា លធ/ខប ត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យជួយផ្សព្វផ្សាយអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋនៅតាមភូមិ ឃុំ សង្កាត់ ហើយជំរុញឱ្យពួកគាត់មកពិនិត្យមើលឈ្មោះ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ជាពិសេសត្រូវបង្រៀនស្មៀនឃុំ សង្កាត់ឱ្យយកចិត្តទុកដាក់ជៀសវាងលើកំហុសបច្ចេកទេសបន្តិចបន្តួចដែលធ្លាប់កើតមានដូចជាៈ

-នៅពេលចុះឈ្មោះសូមសរសេរអក្សរឱ្យច្បាស់ កុំប្រញាប់ប្រញាល់ពេក សុខចិត្តចំណាយពេលយូរបន្តិចចុះ។

-នៅពេលចុះឈ្មោះ ឬកែតម្រូវទិន្នន័យក៏ត្រូវយកចិត្តទុកដាក់ដែរ ជៀសវាងលុបឈ្មោះច្រឡំ ឬកែតម្រូវទិន្នន័យមិនបានត្រឹមត្រូវ។

ឯកឧត្តមបានណែនាំមន្ត្រី លធ/ខប ទាំងអស់ឱ្យមានស្មារតីទទួលខុសត្រូវខ្ពស់ព្រោះថាក្រោយការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតគេនឹងមើលមកយើង ហើយធ្វើសវនកម្មលើបញ្ជីបោះឆ្នោត តើយើងបានធ្វើការងារត្រឹមត្រូវដែរឬទេ? ហើយបញ្ជីបោះឆ្នោតដែលត្រឹមត្រូវគេមើលលើលក្ខខណ្ឌ**៣**យ៉ាងៈ

-ភាគរយអ្នកទៅចុះឈ្មោះបោះឆ្នោតបានច្រើនឬទេ?







# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



-ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតបានត្រឹមត្រូវឬទេ? ដូចជាការលុបឈ្មោះឬកែតម្រូវទិន្នន័យជាដើម។

-ភាពត្រឹមត្រូវលើបញ្ជីបោះឆ្នោត ថាតើការចុះឈ្មោះនេះត្រឹមត្រូវដែរឬទេ? មានការសរសេរខុសច្រើនដែរឬអត់?

ឯកឧត្តមបានបន្ថែមថា ចំណុចទាំងអស់ដែលលើកឡើងខាងលើនេះហើយដែលយើងត្រូវយកចិត្តទុកដាក់ ព្រោះវាជាការងារដ៏មានសារៈសំខាន់។ បើគិតពីការចំណាយថវិកាវិញត្រូវចំណាយអស់ពាក់កណ្តាលនៃការចំណាយលើការបោះឆ្នោតទាំងមូល ប៉ុន្តែស្ថាប័នខ្លះមើលឃើញថាការបោះឆ្នោតមានសារៈសំខាន់នៅពេលឃោសនាបោះឆ្នោត ឬបោះឆ្នោតទេវិញ។

នៅក្នុងពិធីនោះដែរឯកឧត្តមប្រធាន គ.ជ.ប បានលើកឡើងពីសភាពការណ៍ទូទៅផងដែរដោយបញ្ជាក់ថា ថ្មីៗនេះមានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានលើកសរសើរពីការបោះឆ្នោតដូចជា នៅអាហ្វហ្គានីស្ថាន បង់ក្លាដែសជាដើមថា ជាការបោះឆ្នោតធ្វើឡើងបានល្អគួរយកគំរូតាម ប៉ុន្តែអង្គការទាំងនោះមិនដែលសរសើរពីការបោះឆ្នោតនៅកម្ពុជាទេ បើទោះណាជាសហគមន៍អន្តរជាតិបានវាយតំលៃការបោះឆ្នោតនៅកម្ពុជាដូចជានៅឆ្នាំ១៩៩៨ថា ជាអច្ឆរិយនៅដងទន្លេមេគង្គក៏ដោយ ហើយក្រោយមកទៀតនៅឆ្នាំ២០០២ ២០០៣ ២០០៨ គឺគេវាយតំលៃថាល្អជាងការបោះឆ្នោតមុនៗ មានន័យថាពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយវាកាន់តែប្រសើរឡើងៗ។



# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



វគ្គបណ្តុះបណ្តាលដូចគ្នានេះដែរត្រូវបានបើក នៅថ្នាក់លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត(លធ/ខប)ចាប់ពីថ្ងៃទី២២_២៣ ខែសីហា និងនៅតាមមណ្ឌលប្រមូលផ្តុំថ្នាក់ស្រុក ខណ្ឌ ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១។

លោកស្រី នួន ចាន់ទី ប្រធាន លធ/ខប ខេត្តកំពង់ឆ្នាំងបានថ្លែងថា ថ្ងៃនេះលោកស្រីកំពុងធ្វើការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន ជំនួយការស្មៀន និងមន្ត្រីអាជ្ញាធរដែនដីនៅតាមស្រុករួមមានស្រុកកំពង់ត្រឡាច ស្រុកកំពង់លែង និងស្រុកបរិបូរណ៍ ហើយតាមកម្មវិធីការបណ្តុះបណ្តាលត្រូវធ្វើពីថ្ងៃទី២៦_២៧_២៨ ខែសីហា។ លោកស្រីបន្តថាឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សា៥នាក់ យើងអញ្ជើញសមាជិក១នាក់ ហើយឃុំ សង្កាត់ដែលមានសមាជិក៧នាក់ ៩នាក់ ១១នាក់ យើងអញ្ជើញ២នាក់ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាល។ ចំពោះអាជ្ញាធរដែនដីមានអភិបាលស្រុក ប្រធានក្រុមប្រឹក្សាក្រុង ស្រុក និងអធិការនគរបាលក្រុង ស្រុកក៏ត្រូវបានអញ្ជើញចូលរួមផងដែរ។



លោក មាង ម៉េងហ៊ួន ប្រធាន លធ/ខប ខេត្តកំពង់ចាមបានមានប្រសាសន៍ថា តាមកម្មវិធីការបណ្តុះបណ្តាលនឹងត្រូវធ្វើនៅថ្ងៃទី២៧_២៨_២៩ ខែសីហា ហើយទីតាំងបណ្តុះបណ្តាលមាន៥កន្លែងរួមមាន: ទី១ស្រុកពញាក្រែក ទី២ក្រុងសួង ទី៣ស្រុកព្រៃឈរ ទី៤ស្រុកកងមាស និងទី៥ស្រុកស្ទឹងត្រង់ និងក្រុងកំពង់ចាម។

លោក អ៊ុង ស៊ីយឿន ប្រធាន លធ/ខប ខេត្តក្រចេះបានថ្លែងថា ការបណ្តុះបណ្តាលបានចាប់ផ្តើមតាំងពីថ្ងៃទី២៥ ខែសីហា។ លោកបានបញ្ជាក់ថា នៅថ្ងៃទី២៦ ខែសីហានេះកំពុងធ្វើការបណ្តុះបណ្តាលនៅក្នុងស្រុកសំបូរ ហើយនៅថ្ងៃទី២៨ ខែសីហានឹងធ្វើនៅស្រុកស្នួល ស្រុកឆ្លូង និងស្រុកព្រែកប្រសព្វ។



វគ្គបណ្តុះបណ្តាលនៅ លធ/ខប ខេត្តក្រចេះ

តាមការបញ្ជាក់របស់ប្រធាន លធ/ខប ទាំងនោះបានឱ្យដឹងថា វគ្គបណ្តុះបណ្តាលនេះពុំមានអញ្ជើញតំណាងគណបក្សនយោបាយ អង្គការសង្កេតការណ៍បោះឆ្នោតចូលរួមទេ ពីព្រោះតំណាងស្ថាប័នទាំងនេះត្រូវបានអញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលថ្នាក់ លធ/ខប រួចហើយកាលពីថ្ងៃទី២២_២៣ ខែសីហា ឆ្នាំ២០១១៕





# លេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តមណ្ឌលគិរី បើកវគ្គបណ្តុះបណ្តាល ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១

តាមប្រតិទិនការងារ ការបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន ជំនួយការស្មៀន និងមន្ត្រីអាជ្ញាធរមូលដ្ឋានត្រូវបាន លធ/ខប ទាំង២៤ ធ្វើការបណ្តុះបណ្តាលចាប់ពីថ្ងៃទី២៥ដល់២៩ ខែសីហា ឆ្នាំ២០១១។

លោក ទី ឈឿន ប្រធាន លធ/ខប ខេត្តមណ្ឌលគិរីថ្លែងឱ្យដឹងថា ការបើកវគ្គបណ្តុះបណ្តាលមណ្ឌលប្រមូលផ្តុំក្រុមប្រឹក្សាឃុំ សង្កាត់នៅខេត្តមណ្ឌលគិរីត្រូវធ្វើឡើងចំនួន២ថ្ងៃ គឺនៅថ្ងៃទី២៧_២៨ ខែសីហា ឆ្នាំ២០១១។ នៅថ្ងៃទី២៧ ខែសីហាបានធ្វើការបណ្តុះបណ្តាលចំនួន១៥ឃុំ សង្កាត់ នៅសាលប្រជុំគណៈកម្មាធិការប្រតិបត្តិខេត្ត ដែលមានសិក្ខាកាមសរុបចំនួន៤២នាក់ ក្នុងនោះមានអាជ្ញាធរដែនដីពាក់ព័ន្ធចំនួន១០នាក់ និងក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនចំនួន៣២នាក់។

នៅថ្ងៃទី២៨ ខែសីហាបានធ្វើការបណ្តុះបណ្តាលចំនួន៦ឃុំ សង្កាត់ នៅអនុវិទ្យាល័យហ៊ុនសែនកោះញែក ស្រុកកោះញែក មានសិក្ខាកាមសរុបចំនួន២១នាក់ ក្នុងនោះអាជ្ញាធរពាក់ព័ន្ធ៩នាក់ និងក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនចំនួន១២នាក់។

លោកបានបន្តថា វិធីសាស្ត្របណ្តុះបណ្តាលគឺបញ្ចាំងស្លាយ(LCD) និងពន្យល់ខ្លឹមសារជាក់ស្តែងតាមសៀវភៅណែនាំស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១។ ការចោទជាសំណួរឱ្យសិក្ខាកាមឆ្លើយភ្លាមៗ ឱ្យសិក្ខាកាមសួរចំណុចក្នុងឯកសារមេរៀនដែលមិនទាន់យល់ច្បាស់។ បង្ហាញពីការវេចខ្ចប់សម្ភារៈ និងទម្រង់បែបបទផ្សេងៗ។

លោក ទី ឈឿន បានធ្វើការវាយតម្លៃកម្រិតយល់ដឹងរបស់សិក្ខាកាមក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាលឃើញថា សិក្ខាកាមមានការយល់ដឹងបានល្អ៨០ភាគរយ យល់ដឹងល្អបង្គួរ១០ភាគរយ នឹងយល់ដឹងបង្គួរ៥ភាគរយ។

តាមការបញ្ជាក់របស់លោក ទី ឈឿន បានឱ្យដឹងថា វគ្គបណ្តុះបណ្តាលនេះមិនបានអញ្ជើញតំណាងគណបក្សនយោបាយ អង្គការសង្កេតការណ៍បោះឆ្នោតចូលរួមទេ ពីព្រោះតំណាងស្ថាប័នទាំងនេះត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលថ្នាក់ លធ/ខប រួចហើយកាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១៕







# អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលផុតពេលកំណត់ត្រូវបាន បន្តសុពលភាពរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាឯកសារគោលដ៏សំខាន់មួយសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ធ្វើជាឯកសារផ្លូវការផ្សេងៗ ក្នុងនោះមានទាំងសម្រាប់ការចុះឈ្មោះបោះឆ្នោត និងសម្រាប់ការបោះឆ្នោត។ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលអស់សុពលភាពត្រូវបានរាជរដ្ឋាភិបាលកម្ពុជាសម្រេចឱ្យបន្តសុពលភាពរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

តាមខ្លឹមសារអនុក្រឹត្យលេខ១៣២អនក្រ.បក ស្តីពីការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ បានឱ្យដឹងថា ប្រជាពលរដ្ឋដែលកំពុងប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអស់សុពលភាពត្រូវមកបំពេញបែបបទសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតានៅប៉ុស្តិ៍នគរបាលរដ្ឋបាលដែលខ្លួនតាំងទីលំនៅអចិន្ត្រៃយ៍។ រីឯអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលអស់សុពលភាព ហើយអ្នកប្រើប្រាស់មិនទាន់បានបំពេញបែបបទសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតាត្រូវបានបន្តសុពលភាពរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)បានមានប្រសាសន៍ថា កន្លងមកមានការពិភាក្សាទាក់ទងនឹងការងារបោះឆ្នោតជាច្រើនបានលើកឡើងពីការបារម្ភ ដោយសារថាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ប្រជាពលរដ្ឋជាច្រើនត្រូវអស់សុពលភាពប្រើប្រាស់ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការចូលរួមរបស់គាត់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ពិសេសក្នុងការបោះឆ្នោត។ ឥឡូវបញ្ហានេះត្រូវបានដោះស្រាយហើយដោយរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា និងការបន្តសុពលភាពរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ចំពោះអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលអស់សុពលភាពហើយពុំទាន់បានធ្វើទុតិយតា។

ដោយឡែកចំពោះប្រជាពលរដ្ឋដែលពុំមានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក៏ដូចក្នុងការបោះឆ្នោត ឯកឧត្តមបានបញ្ជាក់ថា ពេលនេះ គ.ជ.ប និងក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំរួមមួយ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត។ លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតថ្មីនេះនឹងត្រូវដាក់ឱ្យប្រើជំនួសទម្រង់បែបបទលេខ១០១៨ដែលត្រូវទុកជាមោឃៈ។ ការចេញនីតិវិធីថ្មីនេះគឺដើម្បីធានាដល់សិទ្ធិពលរដ្ឋដែលមានសិទ្ធិក្នុងការចុះឈ្មោះបោះឆ្នោត និងក្នុងការបោះឆ្នោត និងដើម្បីពង្រឹងការគ្រប់គ្រងការស្នើសុំការចេញ និងការប្រើប្រាស់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតថ្មីនេះឱ្យបានរលូនល្អត្រឹមត្រូវ មានគណនេយ្យភាព តម្លាភាព និងបង្ការបាតុភាពមិនប្រក្រតីនានា៕





# បទសម្ភាសន៍ឯកឧត្តម អ៊ឹម សួស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប ជាមួយទូរទស្សន៍ជាតិកម្ពុជា



*ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប ផ្តល់បទសម្ភាសន៍ដល់ទូរទស្សន៍ជាតិកម្ពុជា*

កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ ឯកឧត្តម អ៊ឹម សួស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប បានអនុញ្ញាតឱ្យក្រុមការងារព័ត៌មានរបស់ទូរទស្សន៍ជាតិកម្ពុជាធ្វើការសម្ភាសន៍ទាក់ទងនឹងការងាររៀបចំការបោះឆ្នោត។ បទសម្ភាសន៍នេះត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមរយៈកញ្ចក់ទូរទស្សន៍ជាតិកម្ពុជាកាលពីដើមខែសីហា ឆ្នាំ២០១១ ហើយព្រឹត្តិបត្រព័ត៌មានសូមធ្វើការដកស្រង់ និងចុះផ្សាយខ្លឹមសារទាំងនេះដូចខាងក្រោម៖

**សំណួរ ៖ សូមជម្រាបសួរឯកឧត្តមថា តើបន្ទាប់ពីការបោះឆ្នោតឆ្នាំ២០០៨កន្លងមក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើអ្វីខ្លះ?**

**ចម្លើយ ៖** ជាបឋមខ្ញុំសូមថ្លែងអំណរអគុណដល់ស្ថានីយទូរទស្សន៍ជាតិកម្ពុជាដែលបានមកសម្ភាសន៍នៅពេលនេះ សូមថ្លែងអំណរអគុណផងដែរចំពោះការសហការរវាងស្ថានីយទូរទស្សន៍ជាតិកម្ពុជាជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជានិច្ចជាកាលតែងតែផ្សព្វផ្សាយពីសកម្មភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្រោយឆ្នាំ២០០៨យើងឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានការងារធ្វើជាច្រើនដែរ ដូចជាឆ្នាំ២០០៩កន្លងមកនេះ យើងបានរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩។ ក្រៅពីនោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើ



បច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតរៀងរាល់ឆ្នាំ ជាមួយគ្នានេះដែរគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើការស្រាវជ្រាវអំពីអនុសាសន៍ទាំងឡាយដែលភាគីពាក់ព័ន្ធបានលើកឡើង ហើយយើងបានបង្កើតគណៈកម្មការចម្រុះរវាងគណបក្សនយោបាយ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានUNDP ជាអ្នកសម្របសម្រួល យើងបានរៀបចំជាគណៈកម្មការបច្ចេកទេសចម្រុះរវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដើម្បីសិក្សាស្រាវជ្រាវជុំវិញការងារដែលទាក់ទងនឹងវិសោធនកម្មក៏ដូចជាអនុសាសន៍ទាំងឡាយដែលបានលើកឡើងដោយភាគីពាក់ព័ន្ធ។ ជាមួយគ្នានេះដែរយើងក៏បានធ្វើការសិក្សាស្រាវជ្រាវ ហើយបកប្រែជាភាសាខ្មែរចេញជាសៀវភៅដើម្បីធ្វើការផ្សព្វផ្សាយដល់អ្នកបោះឆ្នោតទាំងឡាយក៏ដូចជាប្រជាពលរដ្ឋឱ្យយល់អំពីអ្វីទៅដែលហៅថាការបោះឆ្នោត មិនមែនតែការបោះឆ្នោតនៅកម្ពុជាទេគឺអោយប្រជាពលរដ្ឋយើង និងមន្ត្រីបោះឆ្នោតទាំងអស់យល់អំពីការបោះឆ្នោតនានានៅក្នុងសកលលោក។ ហើយជាចុងក្រោយនេះនៅឆ្នាំ២០១០ យើងក៏បានចេញសេក្តីណែនាំមួយសំខាន់ពង្រឹងក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅក្នុងនោះសារៈសំខាន់គឺថាយើងចង់ឱ្យអ្នកដែលត្រូវលុបឈ្មោះនោះគឺម្នាក់ៗត្រូវមានឯកសារសំអាងមួយ។

**សំណួរ ៖ ចំពោះឯកឧត្តមផ្ទាល់ តើឯកឧត្តមយល់យ៉ាងដូចម្តេចចំពោះមតិមួយចំនួនថា ការងារបោះឆ្នោតជាការងារធ្វើដដែលៗដូចជាការបោះឆ្នោតកន្លងមកដែរ?**

**ចម្លើយ ៖** ចំពោះបញ្ហានេះបើសិនជាមើលពីចំងាយទៅហាក់ដូចដដែលៗ ប៉ុន្តែបើចូលឱ្យជ្រៅ ហើយយើងថយឱ្យឆ្ងាយបន្តិចយើងឃើញថា យើងមានការវិវត្តន៍ច្រើនណាស់មកទល់នឹងសព្វថ្ងៃនេះ យើងបានធ្វើវិសោធនកម្មច្បាប់បោះឆ្នោតជាបន្តបន្ទាប់ប្រាំពីរលើកមកហើយ បានសេចក្តីថាមុនបោះឆ្នោតនីមួយៗតែងតែមានធ្វើវិសោធនកម្មច្បាប់ដូចជាឆ្នាំ១៩៩៨ យើងមានវិសោធនកម្មរហូតដល់បីដង មុនបោះឆ្នោតឆ្នាំ២០០២ និងឆ្នាំ២០០៣ ក៏យើងធ្វើវិសោធនកម្មដែរ។ ហើយការបោះឆ្នោតឆ្នាំ២០០៨នេះក៏ធ្វើវិសោធនកម្ម ហើយចុងក្រោយនេះទៀតក៏ធ្វើវិសោធនកម្ម ដូច្នេះសរុបមកតាំងពីឆ្នាំ១៩៩៨មក យើងធ្វើវិសោធនកម្មប្រាំពីរដងហើយ ដូច្នេះមិនដដែលៗទេក្រោយពីយើងពិនិត្យអំពីវិសោធនកម្មយើងឃើញថាអ្វីៗគឺវិវត្តន៍ទៅមុខ ហើយមានការងារធ្វើច្រើនណាស់មិនមែនដដែលៗទេ។

**សំណួរ ៖ ចំពោះបញ្ហាទម្រង់១០១៨ត្រូវលុបចោល ហើយជំនួសមកវិញដោយលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត តើករណីនេះមានការខុសគ្នាយ៉ាងដូចម្តេចដែរ?**

**ចម្លើយ ៖** ក្រោយពេលដែលក្រុមបច្ចេកទេសចម្រុះរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប បានចុះទៅធ្វើសិក្ខាសាលានៅតាមភូមិភាគ ទៅតាមខេត្តដើម្បីស្រាវជ្រាវរកមើលអំពីចំណុចខ្លាំង ចំណុចខ្សោយក្នុងការបោះឆ្នោតកន្លងមកឃើញថា ក្រុមបច្ចេកទេសនេះក៏បានស្នើមកក្រសួងមហាផ្ទៃ ក៏ដូចរដ្ឋាភិបាលធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដូចខ្ញុំបានលើកខាងដើម។ វិសោធនកម្មលើកទី៧គឺថាចំណុចសំខាន់មាន៣ ៖

-ទី១ បន្ថែមរយៈពេលនៃការចុះឈ្មោះ ពីមុនបន្ថែមតែ១៥ថ្ងៃទេនៅឆ្នាំដែលមានការបោះឆ្នោតសកល ប៉ុន្តែឥឡូវ





នេះយើងបន្ថែមរហូតទៅដល់៣០ថ្ងៃ។
-ទី២ គឺថាការបិទផ្សាយបញ្ជីដំបូង យើងបិទផ្សាយបញ្ជីដំបូងនៅតាមសាលាឃុំ សង្កាត់ដើម្បីឱ្យប្រជាជនមកមើល រយៈពេលចាស់មានតែ៥ថ្ងៃទេ ហើយសិក្ខាសាលាបានលើកឡើងថារយៈពេលនេះវាខ្លីពេក អញ្ចឹងហើយបានជាធ្វើវិសោធនកម្មរយៈពេលហ្នឹងរហូតថែម៥ថ្ងៃ ដូច្នេះមានរយៈពេល១០ថ្ងៃ។
-ទី៣ ការងារមួយទៀតនោះតាមពិតវាមានហើយការងារផ្ទាល់របស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ប៉ុន្តែយើងសរសេរឱ្យច្បាស់ថែមទៀតគឺការប្រគល់ភារកិច្ចឱ្យគណៈកម្មការឃុំ សង្កាត់ពេលដែលទទួលបានរបាយការណ៍ពីគណៈកម្មការិយាល័យបោះឆ្នោត ហើយគណៈកម្មការឃុំ សង្កាត់ធ្វើការបូកសរុបលទ្ធផលបោះឆ្នោតនៅថ្នាក់ឃុំតែម្តង ហើយបិទលទ្ធផលនេះនៅថ្នាក់ឃុំ សង្កាត់។

ហើយការងារមួយទៀតដែលក្រុមបច្ចេកទេសចម្រុះរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប បានរកឃើញដែរនោះគឺថា មានមតិពីរវាផ្ទុយគ្នា មតិមួយចំនួនចង់ឱ្យលុបចោលទម្រង់១០១៨ មតិដែលចង់លុបមានតិចទេ ប៉ុន្តែមតិមួយទៀតចង់ឱ្យរក្សាទុកឯកសារនេះដដែលដើម្បីឱ្យប្រជាជនដែលអត់មានឯកសារបញ្ជាក់អត្តសញ្ញាណគាត់អាចប្រើទម្រង់នេះធ្វើជាឯកសារចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត ពីព្រោះថាប្រជាជនខ្លះមិនទាន់មានអត្តសញ្ញាណប័ណ្ណទេ ជាពិសេសអ្នកទើបគ្រប់អាយុបោះឆ្នោត អ្នកខ្លះក៏មាន អ្នកខ្លះមិនទាន់មាន ប៉ុន្តែបើយើងមិនមានឯកសារបញ្ជាក់អត្តសញ្ញាណទេយើងមិនអាចចុះឈ្មោះ ឬបោះឆ្នោតបានទេ ដូច្នេះហើយបានជាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រសួងមហាផ្ទៃខិតខំធ្វើយ៉ាងណាចេញសេចក្តីណែនាំមួយក្នុងការពង្រឹងចេញឯកសារដែលយើងហៅឈ្មោះថាឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ហើយឯកសារបញ្ជាក់អត្តសញ្ញាណវាខុសពី១០១៨ដែលយើងធ្លាប់ប្រើពីមុន គឺថាឯកសារមួយដែលមិនអាចថតចម្លងបាន ឬកោសលុប ឬក៏កែអត់បានទេ គឺជាឯកសារមួយមិនអាចធ្វើការកោសលុបបានទេ ហើយឯកសារនេះគឺជាឯកសារមានគល់បញ្ជីមានលេខរៀងត្រឹមត្រូវ ជាពិសេសការចេញឯកសារនេះនៅពេលចុះឈ្មោះ ហើយក្រោយពេលចប់ការចុះឈ្មោះគឺយើងមានរបាយការណ៍ច្បាស់លាស់ដែលត្រូវផ្ញើមកថ្នាក់ស្រុក ខណ្ឌ ខេត្ត រាជធានី រួចហើយផ្ញើមកក្រសួងមហាផ្ទៃ និងផ្ញើមកគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ហើយ គធ/ខប ផ្ញើមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូច្នេះការគ្រប់គ្រងមានការហ្មត់ចត់ណាស់។ ការចេញនៅមុនថ្ងៃបោះឆ្នោត បើសិនជនណាម្នាក់បាត់ឯកសារបញ្ជាក់អត្តសញ្ញាណ ដូចជាបាត់កាតជាដើមអាចមកសុំ ប៉ុន្តែមិនអាចមកសុំរហូតដល់ថ្ងៃបោះឆ្នោតទេ ការចេញឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតគឺឈប់១ថ្ងៃ បានសេចក្តីថាបោះឆ្នោតនៅថ្ងៃអាទិត្យគឺត្រូវឈប់នៅថ្ងៃសុក្រម៉ោង៥ល្ងាច គឺថាមេឃុំ ចៅសង្កាត់លែងចេញឯកសារនេះឱ្យហើយ ថ្ងៃសៅរ៍ធ្វើរបាយការណ៍តាមថ្នាក់នីមួយៗឡើងមកដល់ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូច្នេះការគ្រប់គ្រងនេះមានការហ្មត់ចត់មិនអាចនរណាបន្លំ ឬធ្វើការថតចម្លងបានទេ ហើយយើងដឹងចំនួនចេញឯកសារបញ្ជាក់

# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



អត្តសញ្ញាណមានប៉ុន្មាន។

**សំណួរ : តើការចុះឈ្មោះបោះឆ្នោតមានសារៈប្រយោជន៍អ្វីដែរសុំឱ្យឯកឧត្តមជម្រាបជូនប្រជាពលរដ្ឋ?**

**ចម្លើយ :** ការចុះឈ្មោះបោះឆ្នោតហ្នឹងមានសារៈសំខាន់ណាស់ ជាការពិតយើងម្នាក់ៗកើតមកមានសិទ្ធិបោះឆ្នោតមកជាមួយទៅហើយ គ្រាន់តែយើងបានទៅ ឬមិនបានទៅបំពេញសិទ្ធិទេ។ យើងនឹងមិនអាចបោះឆ្នោតបានទេ ទាល់តែយើងទៅចុះឈ្មោះបោះឆ្នោតដើម្បីឱ្យមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។ ប្រជាពលរដ្ឋត្រូវទៅចុះឈ្មោះខ្លួនឯង ដោយកាន់ឯកសារទៅជាមួយរួមមានៈ ទី១ឯកសារបញ្ជាក់អត្តសញ្ញាណ ទី២ឯកសារបញ្ជាក់សញ្ជាតិ ទី៣ឯកសារបញ្ជាក់ទីលំនៅ និងទី៤ឯកសារបញ្ជាក់ថាអាយុគ្រប់១៨ឆ្នាំ ពីព្រោះថាអាយុ១៨ឆ្នាំឡើងបានមានសិទ្ធិបោះឆ្នោត ដូច្នេះអ្នកទាំងអស់នោះត្រូវទៅចុះឈ្មោះបោះឆ្នោត បើមិនអញ្ចឹងទេមិនមានសិទ្ធិបោះឆ្នោតទេ។

**សំណួរ : ពីមុនមកយើងមានឃុំ សង្កាត់ចំនួន១៦២១ ហើយពេលថ្មីៗនេះរាជរដ្ឋាភិបាលបានបង្កើតឃុំ សង្កាត់ថ្មី និងមានការកែប្រែព្រំប្រទល់ឃុំ សង្កាត់ផងដែរ តើក្នុងបច្ចុប្បន្ននេះមានឃុំ សង្កាត់ចំនួនប៉ុន្មានដែរ? ហើយបញ្ហានេះអាចមានការប៉ះពាល់ដល់ការបោះឆ្នោតយ៉ាងដូចម្តេច?**

**ចម្លើយ :** ថ្មីៗកន្លងមកនេះរដ្ឋាភិបាលបានបង្កើតឃុំ សង្កាត់ និងកែប្រែព្រំទល់ ប៉ុន្តែមិនពាក់ព័ន្ធដល់មនុស្សទេ គ្រាន់តែទាក់ទងដល់ដី យកដីពីកន្លែងមួយទៅកន្លែងមួយពង្រីកឃុំ សង្កាត់ហ្នឹង។

ទាក់ទងដល់បញ្ហាការងារចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត ដោយសារថាកាលណាដូរទីលំនៅទៅឃុំថ្មី គឺថាត្រូវតែមកចុះឈ្មោះឃុំថ្មីហើយ បានជានីតិវិធីនៅក្នុងការធ្វើបញ្ជីឈ្មោះអ្នកបោះឆ្នោតសម្រាប់ឃុំថ្មីនេះយើងបានធ្វើការផ្សព្វផ្សាយរួចរាល់ហើយដោយមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយនានា។ ឃុំដែលបង្កើតថ្មីមកទល់នឹងថ្ងៃនេះមានចំនួន១២ឃុំសង្កាត់ ដូច្នេះពីមុនវាមាន១៦២១ ថែម១២ទៅទៀតវាទៅជា១៦៣៣ឃុំសង្កាត់។

**សំណួរៈ យើងឃើញថាការងាររបស់ គ.ជ.ប មានទំហំធំធេង ហើយការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់មានទំហំធំធេងជាងការបោះឆ្នោតកាលពីឆ្នាំ២០០៧ តើ គ.ជ.ប គម្រោង និងចំណាយថវិកាអស់ប៉ុន្មានដែរសម្រាប់ការរៀបចំការបោះឆ្នោតនៅពេលខាងមុខនេះ?**

**ចម្លើយ :** ការងារដែលត្រូវធ្វើមានច្រើនណាស់ ដោយសារថាឃុំ សង្កាត់បង្កើតថ្មីក៏ច្រើនជាង១០ឃុំ សង្កាត់ ហើយប្រជាពលរដ្ឋដល់អាយុបោះឆ្នោតក៏កើនដែរ ដូច្នេះការងារទាក់ទងដល់បញ្ហានេះវាត្រូវការចំណាយច្រើន តាមគម្រោងដែលយើងប៉ាន់ស្មានមានរហូតដល់២១លានដុល្លារ ហើយសម្រាប់ចុះឈ្មោះនេះយើងចំណាយអស់ជាង៣លានដុល្លារ គ្រាន់តែទាក់ទងដល់ការចុះឈ្មោះប៉ុណ្ណោះទេ។ ដូច្នេះការងារនេះវាមានទំហំមួយធំធេងណាស់ យើងត្រូវពង្រីកធ្វើការផ្សព្វផ្សាយឱ្យបានច្រើន ប៉ុន្តែថវិកាមានកំណត់ដូច្នេះគឺមានការកែសម្រួលថវិកាខ្លះដែលទាក់ទងដល់ការចុះឈ្មោះនេះ។

**សំណួរ : ពីមួយឆ្នាំទៅមួយឆ្នាំ តើឯកឧត្តមអាចពន្យល់បានទេថាតើមានចំនួនប្រជាជនដែលគាត់យល់ពីអត្ថប្រយោជន៍នៃការចុះឈ្មោះបោះឆ្នោតមានការកើនឡើងយ៉ាងដូចម្តេច?**





# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



*សកម្មភាពប្រជាពលរដ្ឋទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត*

**ចម្លើយ :** តាមការស្រាវជ្រាវរបស់អង្គការ NDI ក៏ដូច IRI យើងឃើញថា ពីមួយឆ្នាំទៅមួយឆ្នាំប្រជាពលរដ្ឋមានការយល់ដឹងច្រើនជាងមុនបើប្រៀបធៀបជាមួយឆ្នាំ១៩៩៨ ឬក៏ឆ្នាំ២០០៣ យើងឃើញថាមានការយល់ដឹងច្រើនដោយសារថាប្រជាពលរដ្ឋយើងហាក់បីដូចជាមានទម្លាប់ខ្លះក្នុងការអនុវត្តរបបប្រជាធិបតេយ្យនេះ ដូច្នេះយើងត្រូវមានការទាមទារឱ្យមានការចូលរួមពីប្រជាពលរដ្ឋដើម្បីគាត់យល់ពីសិទ្ធិអំពីការជ្រើសរើសទាំងថ្នាក់ភូមិ ថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត។ ចំពោះការជ្រើសរើសសមាជិកសភា ឬក៏ព្រឹទ្ធសភាគាត់បានយល់អំពីការងារនេះខ្លះហើយ។ ក៏ប៉ុន្តែមានចំណុចខ្សោយ និងចំណុចខ្វះខាតដែរចំពោះយុវជនដល់អាយុហើយ ជួនកាលមិនទាន់បានយល់ជ្រួតជ្រាបនៅឡើយទេ ដូច្នេះការងារនេះមិនមែនមានតែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតម្នាក់ឯងធ្វើទេ ទាមទារឱ្យប្រជាពលរដ្ឋទាំងមូល អង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយទាំងអស់ចូលរួមបំផុសធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋក្មេងៗដល់អាយុបោះឆ្នោតឱ្យពួកគាត់មកចុះឈ្មោះបានគ្រប់គ្នា។

**សំណួរ : ជាចុងក្រោយនេះ តើឯកឧត្តមមានប្រសាសន៍ណែនាំអ្វីខ្លះដល់ប្រជាពលរដ្ឋរបស់យើង?**

**ចម្លើយ :** ខ្ញុំសូមអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ជាពិសេសយុវជនដែលដល់អាយុបោះឆ្នោត សុំឱ្យចូលរួមឱ្យបានច្រើននៅតាមឃុំ សង្កាត់ដែលធ្លាប់រស់នៅ និងចូលមកបង្ហាញខ្លួនដើម្បីចុះឈ្មោះបោះឆ្នោត ពីព្រោះថាបើសិនមិនមានឈ្មោះបោះឆ្នោតនៅពេលខាងមុខនេះទេ មិនបានចុះឈ្មោះទេ មិនអាចបោះឆ្នោតនៅថ្ងៃទី៣ ខែមិថុនាបានទេ ហើយថ្ងៃទី៣ ខែមិថុនា ទាល់តែអ្នកនោះមានឈ្មោះបោះឆ្នោត និងមានឯកសារបញ្ជាក់អត្តសញ្ញាណទើបបោះឆ្នោតបាន។ ដូច្នេះសូមអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់ និងជាពិសេសយុវជនដែលដល់អាយុបោះឆ្នោតសុំឱ្យរហ័សរហួនឡើងនៅពេលចុះឈ្មោះខាងមុខនេះ សុំឱ្យចុះឈ្មោះឱ្យបានច្រើនគ្រប់ៗគ្នា៕

ក្រុមរៀបចំព្រឹត្តិបត្រព័ត៌មាន គ.ជ.ប
អ្នកគ្រប់គ្រង លោក ម៉ែ សារី

ក្រុមនិពន្ធ
លោក ជា សែ
លោក សុខ លាភ

កំណែអក្ខរាវិរុទ្ធ
អ្នកស្រី ទិន សាវត្ថី

អ្នកថតរូប
លោក សាក់ បូរិន

ក្រាហ្វិកកុំព្យូទ័រ
លោក ប៉េង រតនៈ
លោក ចាន់ វិបុល



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១

## ប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១

| ការកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការចុះឈ្មោះអ្នកសង្កេតការណ៍ | ថ្ងៃទី ១៧ ខែ សីហា - ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១១ |
| ការចុះឈ្មោះតំណាងគណបក្សនយោបាយ | ថ្ងៃទី ២៥ ខែ សីហា - ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១១ |
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១១ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ (បញ្ជីបោះឆ្នោតឆ្នាំ២០១០) នៅសាលាឃុំ សង្កាត់ | ថ្ងៃទី ៣០-៣១ ខែ សីហា ឆ្នាំ ២០១១ |
| ការចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ | ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១១ |
| ការបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ | ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១១ |
| ការប្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការប្តឹងតវ៉ានឹងការបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការប្តឹងតវ៉ានឹងការបដិសេធរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង (តាមករណីគ្មាន ឬមានបណ្តឹង) | ថ្ងៃទី ១៥ ខែ តុលា - ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ |
| ការប្តឹងតវ៉ា ឬជំទាស់លើបញ្ជីបោះឆ្នោតដំបូងទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការប្តឹងតវ៉ា ឬជំទាស់នឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការប្តឹងតវ៉ា ឬជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១ ( **ថ្ងៃចុងក្រោយ** ) |
| ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតឆ្នាំ២០១១ ដោយ គ.ជ.ប | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ |





# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១១

## ប្រតិទិននៃការបោះឆ្នោតឡើងវិញជ្រើសរើស ក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យនៃរាជធានីភ្នំពេញ ឆ្នាំ២០១១

| ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១១ |
| ការស្រង់ឈ្មោះអ្នកបោះឆ្នោត និងការបញ្ជូនមក គ.ជ.ប | ថ្ងៃទី ២១-៣០ ខែកញ្ញា ឆ្នាំ២០១១ |
| ការរៀបចំបញ្ជីបោះឆ្នោត | ថ្ងៃទី ០១-១០ ខែតុលា ឆ្នាំ២០១១ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៅតាមសាលាសង្កាត់ ខណ្ឌ | ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១១ |
| ការប្តឹងតវ៉ា ឬជំទាស់លើបញ្ជីបោះឆ្នោតដំបូង និងការដោះស្រាយបណ្តឹងនៅ គធប | ថ្ងៃទី ១២-១៥ ខែតុលា ឆ្នាំ២០១១ |
| ការប្តឹងតវ៉ា ឬជំទាស់លើបញ្ជីបោះឆ្នោតដំបូង និងការដោះស្រាយបណ្តឹងនៅ គ.ជ.ប | ថ្ងៃទី ២០-៣០ ខែតុលា ឆ្នាំ២០១១ |
| ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត | ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១១ |
| ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះបោះឆ្នោត | ថ្ងៃទី ១៤-១៨ ខែកញ្ញា ឆ្នាំ២០១១ |
| ការកែតម្រូវចុងក្រោយរបស់គណបក្សនយោបាយ និងការពិនិត្យសម្រេចដោយ គ.ជ.ប | ថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១១ ( ថ្ងៃចុងក្រោយ) |
| ការចាប់ឆ្នោតកំណត់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត | ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១១ ( ថ្ងៃចុងក្រោយ) |
| ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត | ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១១ ( ថ្ងៃចុងក្រោយ) |
| ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅសាលាសង្កាត់ និងទីសាធារណៈក្នុងមណ្ឌល | ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១១ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការនៅការិយាល័យបោះឆ្នោត និងនៅទីសាធារណៈក្នុងមណ្ឌល | ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១១ |
| ការឃោសនាបោះឆ្នោត | ថ្ងៃទី ២៥ ខែវិច្ឆិកា ដល់ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១១ |
| ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត | ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១១ |
| ការប្តឹងតវ៉ាពីភាពមិនប្រក្រតីនៅការិ.បោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតទៅ គធប ក្នុងរយៈពេល ២ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ឬបិទផ្សាយ | ថ្ងៃទី ១២-១៣ ខែធ្នូ ឆ្នាំ២០១១ |
| ការដោះស្រាយបណ្តឹងតវ៉ាដោយ គធប ក្នុងរយៈពេល ៣ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបណ្តឹង | ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១១ ( ថ្ងៃចុងក្រោយ) |
| ការបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅ គធប | ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១១ ( ថ្ងៃចុងក្រោយ) |
| ការប្តឹងតវ៉ាពីការសម្រេចរបស់ គធប ឬពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ទៅ គ.ជ.ប ក្នុងរយៈពេល ៣ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចរបស់ គធប ឬថ្ងៃបិទផ្សាយ | ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១១ ( ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយ គ.ជ.ប ក្នុងរយៈពេល ៣ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបណ្តឹង | ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១១ ( ថ្ងៃចុងក្រោយ) |
| ការបោះឆ្នោតសាជាថ្មី ៨ថ្ងៃ ក្រោយការសម្រេចរបស់ គ.ជ.ប ( ប្រសិនបើមាន) | ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១១ ( ថ្ងៃចុងក្រោយ) |
| ការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត ( ករណីគ្មានការបោះឆ្នោតសាជាថ្មី) | ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១១ ( ថ្ងៃចុងក្រោយ) |



# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១១

## ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣ ឆ្នាំ២០១២

| ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការដោយ គ.ជ.ប | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ |
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោតនៅ គឃ/សប | ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ |
| ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដោយ គឃ/សប | ថ្ងៃទី ០១-០៣ ខែ មីនា ឆ្នាំ ២០១២ |
| ការពិនិត្យ សម្រេចរបស់ គឃ/សប លើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ | ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការកែតម្រូវលើពាក្យសុំចុះបញ្ជីបេក្ខជនដោយគណបក្សនយោបាយសាមី | ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការប្តឹងតវ៉ា និងការដោះស្រាយបណ្តឹងទាក់ទងការសុំចុះបញ្ជីបេក្ខជន នៅ គធ/ខប | ថ្ងៃទី ១៧ - ២៤ ខែ មីនា ឆ្នាំ ២០១២ |
| ការប្តឹងតវ៉ា និងការដោះស្រាយបណ្តឹងទាក់ទងនឹងការសុំចុះបញ្ជីបេក្ខជន នៅ គ.ជ.ប | ថ្ងៃទី ២៥ ខែ មីនា - ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១២ |
| ការបិទផ្សាយបញ្ជីបេក្ខជនដំបូងនៅ គឃ/សប | ថ្ងៃទី ០២-០៤ ខែ មេសា ឆ្នាំ ២០១២ |
| ការប្តឹងជំទាស់នឹងបញ្ជីបេក្ខជនដំបូងទៅ គ.ជ.ប រយៈពេល ៣ ថ្ងៃ | ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងទាក់ទងនឹងបញ្ជីបេក្ខជនដំបូងដោយ គ.ជ.ប រយៈពេល ៣ ថ្ងៃ | ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការបិទផ្សាយបញ្ជីបេក្ខជនផ្លូវការនៅ គឃ/សប | ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការឃោសនាបោះឆ្នោត | ថ្ងៃទី១៨ ខែឧសភា - ថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០១២ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោត | ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១២ |
| ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត | ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១២ |
| ការប្រកាសផ្សាយលទ្ធផលបឋមនៃការបោះឆ្នោតដោយ គ.ជ.ប | ថ្ងៃទី០៣ - ០៤ ខែមិថុនា ឆ្នាំ២០១២ |
| ការត្រួតពិនិត្យ បូកសរុប និងបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៅ គឃ/សប | ថ្ងៃទី ០៤ - ០៦ ខែ មិថុនា ឆ្នាំ ២០១២ |
| ការប្តឹងជំទាស់ពីលទ្ធផលបណ្តោះអាសន្នតាមឃុំ សង្កាត់ ទៅ គធ/ខប រយៈពេល ៣ ថ្ងៃ | ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការសម្រេចលើបណ្តឹងជំទាស់ដោយ គធ/ខប រយៈពេល ៥ ថ្ងៃ | ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់ គធ/ខប ទៅ គ.ជ.ប រយៈពេល ៤ ថ្ងៃ | ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការសម្រេចលើបណ្តឹងតវ៉ាដោយ គ.ជ.ប រយៈពេល ៤ ថ្ងៃ | ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការប្រកាសផ្សាយលទ្ធផលផ្លូវការនៃការបោះឆ្នោត | ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការបោះឆ្នោតសាជាថ្មី ( ប្រសិនបើមាន ) | ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១១

# សេចក្តីជូនដំណឹង

ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើង មានសិទ្ធិនឹងទទួលបានសិទ្ធិបោះឆ្នោត ។ ដើម្បីកុំឱ្យបាត់បង់សិទ្ធិបោះឆ្នោតនេះ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (គ.ជ.ប) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់មេត្តាជ្រាបថា ៖

- ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ ២០១១ ដែលចាប់ផ្តើមនៅគ្រប់ឃុំ សង្កាត់ពី **ថ្ងៃទី ០១ ខែ កញ្ញា ដល់ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១១** មានសារៈសំខាន់ណាស់ ព្រោះបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១១ គឺសម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣ **នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១២** ។
- ប្រជាពលរដ្ឋដែលពុំទាន់បានចុះឈ្មោះបោះឆ្នោត ពិសេសយុវជន យុវនារី ដែលទើបតែគ្រប់អាយុបោះឆ្នោត គឺអាយុ ១៨ ឆ្នាំ គិតដល់ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១២ អ្នកផ្លាស់ទីលំនៅចូល ឬអ្នកពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោត សូមអញ្ជើញទៅចុះឈ្មោះបោះឆ្នោត នៅតាមសាលាឃុំ សង្កាត់ ឬនៅទីតាំងណាមួយក្នុងឃុំ សង្កាត់ដែលបងប្អូនកំពុងរស់នៅ ។
- ប្រជាពលរដ្ឋដែលមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហើយត្រូវអស់សុពលភាព និងមិនទាន់បានសុំធ្វើឡើងវិញ ក៏អាចយកអត្តសញ្ញាណប័ណ្ណនោះទៅចុះឈ្មោះបោះឆ្នោតបានដែរ ព្រោះថាវាអាចបន្តសុពលភាពប្រើប្រាស់រហូតដល់**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣** ។
- ប្រជាពលរដ្ឋដែលពុំមានឯកសារបញ្ជាក់អត្តសញ្ញាណ សម្រាប់បំពេញលក្ខខណ្ឌក្នុងការចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត មានសិទ្ធិស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ដោយត្រូវទៅបង្ហាញខ្លួនផ្ទាល់នៅចំពោះមុខមេឃុំ ចៅសង្កាត់ ហើយនាំទៅជាមួយនូវរូបថតសាមីខ្លួនចំនួនពីរ (២)សន្លឹក និងសាក្សីពីររូប ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ។
- ប្រជាពលរដ្ឋដែលមានសាច់ញាតិទទួលមរណភាព ឬផ្លាស់ទីលំនៅចេញពីឃុំ សង្កាត់ ឬមានឈ្មោះស្ទួន ឬមានឈ្មោះនិងទិន្នន័យមិនត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោត សូមរាយការណ៍ជូនស្មៀនឃុំ សង្កាត់ ដើម្បីលុបឈ្មោះចេញ ឬកែតម្រូវទិន្នន័យក្នុងបញ្ជីបោះឆ្នោត ។

អាស្រ័យហេតុនេះ គ.ជ.ប សូមអញ្ជើញបងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ ទៅចូលរួមធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឱ្យបានទាន់ពេលវេលា ។៚

**សូមអរគុណ!**